**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៣
ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០
-សាលក្រមព្រហ្មទណ្ឌលេខ: ៧៥ "ឆ"
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២៣ វេលាម៉ោង ២ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសេចក្តីចម្លងបណ្តឹងទាស់លេខ: ២៥/២០២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ: ៦២៣ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ:

-ឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរទិញអេតចាយ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តតាកែវ និងមានទីលំនៅមុនពេលឃាត់ខ្លួននៅភូមិ[redacted]ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **សុង** (ស្លាប់) ម្តាយឈ្មោះ [redacted] **រ៉ូម** (រស់) មានប្រពន្ធឈ្មោះ [redacted] **សោភ័ណ្ឌ** (រស់) មានកូន ០២នាក់ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៨ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ: គ្មាន។ (ឃុំខ្លួនថ្ងៃទី២៦-០៦-២០២៣)

ជាប់ចោទពីបទ: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និង មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] មានអត្តលេខ: [redacted] ជា មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអឿន**។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឌីណា** ភេទប្រុស អាយុ២១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ។

-បានឃើញ របាយការណ៍លេខៈ ១៧៦/២០២០ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ០៣៧ ដ.ស.ព/២១ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៧៣ (ង)/២០២១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាបង្គាប់ឱ្យចាប់ខ្លួនពិរុទ្ធជនលេខៈ ១០៨/ត្រ.ព ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ សេចក្ដីចម្លងបណ្ដឹងទាស់លេខៈ ២៥/២០២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន**។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះបន្តលេខៈ ២១៨៦ ដចត/២០២៣ ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញ ឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

## អង្គហេតុដែលបានប្ដឹងមកតុលាការមានដូចតទៅ:

កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង១១ និង៣០នាទី នៅចំណុចភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ មានករណីអំពើលួចម៉ូតូមួយបានកើតឡើង បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ស៊ីដេត** ភេទប្រុស អាយុ៣៥ឆ្នាំ បានធ្វើសកម្មភាពលួចយកម៉ូតូមួយគ្រឿងម៉ាកស៊ូម៉ីអ៊ិចពណ៌បៃតង ពាក់ស្លាកលេខ៖10-0480 លេខតួៈ 5117526 និងលេខម៉ាស៊ីនៈ 0117526 ដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] **ឌីណា** ភេទប្រុស អាយុ ២១ឆ្នាំ ហើយជនជាប់ចោទនេះក៏ជិះម៉ូតូគេចខ្លួនបាត់។ ក្រោយមកជនរងគ្រោះដាក់ពាក្យបណ្ដឹងមកសមត្ថកិច្ច ហើយសមត្ថកិច្ចបានកំណត់មុខសញ្ញាធ្វើការឃាត់ខ្លួនជនជាប់ចោទនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០។ បន្ទាប់មកជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនបានយកម៉ូតូទៅលក់ឱ្យអ្នកទិញអេតចាយមួយកន្លែងស្ថិតនៅចំណុចខាងជើងផ្សារសំរោងយ៉ាង ប្រហែល៥គីឡូម៉ែត្រ ផ្ទះខាងលិចផ្លូវ ដោយបានប្រាក់ចំនួន១០ម៉ឺនរៀល ទើបសមត្ថកិច្ចធ្វើការកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានឆ្លើយថាៈ ចំពោះរឿងហេតុដែលបានចោទប្រកាន់នេះខ្ញុំបាទពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយខ្ញុំមិនបានទិញម៉ូតូពីឈ្មោះ [redacted] **ស៊ីដេត** នោះទេ។ ដោយនៅថ្ងៃដែលមានរឿងហេតុនោះ គឺមានឈ្មោះ [redacted] **ស៊ីដេត** បានបណ្ដើរម៉ូតូមួយគ្រឿងយកមកលក់នៅកន្លែងឃ្លាំងអេតចាយរបស់ខ្ញុំបាទ ហើយនៅពេលនោះដែរខ្ញុំបាទនិយាយថាមិនទទួលទិញនោះទេ ហើយឈ្មោះ [redacted] **ស៊ីដេត** នេះក៏បានបណ្ដើរម៉ូតូនោះចេញទៅដោយខ្ញុំមិននបានចាប់អារម្មណ៍នោះទេ។ ហើយក្រោយមកក៏



Scanned with CamScanner

មានសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] **ស៊ីដេត** នេះដោយបានដើរមកចង្អុលថាបានលក់ឱ្យមកខ្ញុំ តែតាមការពិតខ្ញុំមិនបានទិញនោះទេ។ ហើយសមត្ថកិច្ចបានឱ្យឈ្មោះ [redacted] ស៊ីដេត នោះដើរចង្អុលបង្ហាញ ដោយពេលនោះដែរសមត្ថកិច្ចបាននិយាយថា "កុំចេះតែចង្អុលចោទប្រកាន់ផ្តេសផ្តាស"។ ចំពោះឈ្មោះ [redacted] ស៊ីដេត នេះខ្ញុំមិនដែលស្គាល់គេសូម្បីតែបន្តិចសោះ ហើយឈ្មោះនេះក៏មិនដែលយកអ្វីផ្សេងៗកន្លងមកៗលក់ឱ្យខ្ញុំបាទនោះទេ។ ខ្ញុំរកស៊ីប្រកបរបរទិញអេតចាយអស់រយៈពេលជិត ២៥ឆ្នាំមកហើយ។ ខ្ញុំមិនដែលស្គាល់ និងមិនដែលមានគំនុំជាមួយនឹងឈ្មោះ [redacted] **ស៊ីដេត** នោះទេ។ មូលហេតុដែលខ្ញុំបាទមិនទទួលទិញម៉ូតូពីឈ្មោះ [redacted] ស៊ីដេត នោះ គឺដោយហេតុថាម៉ូតូដែលគេយកមកនោះពុំមានឯកសារគ្រប់គ្រាន់នោះទេ ទើបខ្ញុំពុំហ៊ានទទួលទិញ។ ខ្ញុំបាទសូមបញ្ជាក់បន្ថែមថា: នៅថ្ងៃដែលមានឈ្មោះ [redacted] **ស៊ីដេត** យកម៉ូតូនោះមកលក់ឱ្យខ្ញុំនោះ គឺខ្ញុំបាទបានដកទូរស័ព្ទខ្ញុំថតរូបគេទុកដែរ មូលហេតុដែលខ្ញុំថតរូបទុកនោះ គឺដោយហេតុថាខ្លាចមានបញ្ហារកើតឡើងទៅថ្ងៃក្រោយ។ កន្លងមកខ្ញុំធ្លាប់ទទួលទិញម៉ូតូចាស់ៗរបស់អ្នកស្រុកភូមិខ្លះៗដែរ ដែលសុទ្ធតែជាម៉ូតូចាស់ៗដើម្បីយកមកថ្លឹងគីឡូលក់កាន់សាច់តិចតួចៗ ដោយម៉ូតូដែលចាស់ៗទាំងនោះភាគច្រើនពុំមានឯកសារនោះទេ។ ខ្ញុំសូមបន្ថែមថា: ចំពោះមូលហេតុដែលខ្ញុំថតរូបរបស់ឈ្មោះ [redacted] **ស៊ីដេត** ដែលបានបណ្តើរម៉ូតូមកលក់ឱ្យខ្ញុំនោះ គឺដើម្បីការពារខ្លាចមានគេរកម៉ូតូទៅងាយស្រួលប្រាប់គេតទៅទៀត។

-សាក្សីឈ្មោះ [redacted] **រិទ្ធិ** បានឆ្លើយថា: នៅពេលនេះខ្ញុំបាទបានស្បថរួចហើយៗចំពោះរឿងហេតុដែលមាននៅពេលនេះ គឺខ្ញុំគ្រាន់តែបានដឹងថាមានឈ្មោះ [redacted] **ស៊ីដេត** បានលួចម៉ូតូរបស់ឈ្មោះ [redacted] **ឌីណា** ហើយពេលគេលួចហើយនោះ គឺបានជិះចេញទៅបាត់ ចំណែកឈ្មោះ [redacted] **ស៊ីដេត** យកទៅលក់ឱ្យនរណាគេនោះ គឺខ្ញុំពុំដឹងនោះទេ។ ចំពោះរឿងហេតុផ្សេងទៀតខ្ញុំបាទពុំដឹងនោះទេ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **ស៊ីដេត** បានឆ្លើយថា: កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០២០ វេលាម៉ោងប្រហែល ១១ និង ៣០នាទីព្រឹក ខ្លួនពិតជាបានលួចម៉ូតូម៉ាកស៊ូម៉័រអ៊ិច ពណ៌បៃតង នៅភូមិត្រពាំងកក់ ឃុំពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដែលជារបស់ឈ្មោះ [redacted] ឌីណា ប្រាកដមែន ដោយពេលនោះខ្លួនឃើញម៉ូតូរបស់ឈ្មោះ [redacted] ឌីណា បញ្ឈរទុកនៅមុខផ្ទះដោយមានសោរនៅជាប់នឹងម៉ូតូ ហើយម៉ូតូនោះបានដួល ពេលនោះខ្លួនក៏ទៅលើកម៉ូតូនោះ ស្រាប់តែឈ្មោះ [redacted] ឌីណា ចេញមកឃើញហើយស្រែកថាចោរៗ ខ្លួនក៏បញ្ឆេះម៉ូតូនោះជិះរត់តែម្តងទៅពុំមានអ្នកណាតាមទាន់នោះទេ។ បន្ទាប់មកខ្លួនជិះម៉ូតូនោះទៅជិតដល់ផ្សារសំរោងយ៉ាងម៉ូតូនោះក៏រលត់លែងឆេះតែម្តង ហើយខ្លួនក៏យកម៉ូតូនោះលក់ឱ្យអ្នកទិញអេតចាយឈ្មោះ [redacted] **សំអឿន** មួយកន្លែងស្ថិតនៅចំណុចខាងជើងផ្សារសំរោងយ៉ាងប្រហែល ៥គីឡូម៉ែត្រ ផ្ទះខាងលិចផ្លូវតែម្តងទៅ ដោយលក់បានប្រាក់ចំនួន ១០ម៉ឺនរៀល។ ក្រោយពីខ្លួនលក់ម៉ូតូនោះបានប្រាក់ហើយខ្លួនបានរត់គេចខ្លួនទៅខេត្តកំពង់ចាម នៅផ្ទះឪពុករបស់ខ្លួន។ លុះនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ខ្លួនក៏ត្រឡប់មកលេងកូន និងប្រពន្ធខ្លួនវិញក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តងទៅ។ ពេលដែលខ្លួណធ្វើសកម្មភាពលួចម៉ូតូគេនោះ គឺខ្លួនធ្វើសកម្មភាពតែម្នាក់ឯងតែប៉ុណ្ណោះ ពុំមានបក្ខពួកនោះទេ។ ខ្លួនមិនធ្លាប់ធ្វើសកម្មភាពលួចគេពីមុនមកនោះទេ ទើបតែលើកទី១ នេះតែប៉ុណ្ណោះ។ ខ្លួនសុំសំណូមពរដល់តុលាការឱ្យជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ឌីណា** បានឆ្លើយថា: កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០២០ ខ្លួនមកពីផ្សារទិញម្ហូប រួចក៏បានចូលទៅក្នុងផ្ទះដើម្បីចំអិនម្ហូបដែលស្ថិតនៅភូមិត្រពាំងកក់ ឃុំពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដោយបញ្ឈរម៉ូតូរបស់ខ្លួនម៉ាក ស៊ូទ័រអ៊ិច ពណ៌បៃតងពាក់ស្លាក់លេខ 1O-0480 ទុក

នៅខាងមុខផ្ទះដោយមិនបានដកសោរទុក បានប្រហែលជាកន្លះម៉ោងខ្លួនក៏ឮសំឡេងគបណ្តើរម៉ូតូក៏ចេញមកមើល ស្រាប់តែឃើញចោរលួចម៉ូតូ តែខ្លួនចាប់មិនបានទេ ព្រោះចោរបានឡើងជិះម៉ូតូខ្លួនកាច់សោរបញ្ឆះរួចបាត់ទៅហើយ ម្យ៉ាងទៀតខ្លួនមិនមានមធ្យោបាយណាមួយដើម្បីតាមចាប់យកម៉ូតូមកវិញឡើយ មានតែស្រែកហៅអ្នកក្បែរជួយចាប់ចោរ តែនៅតែចាប់មិនបានឡើយ បន្ទាប់មកខ្លួនក៏បានទៅប្តឹងសមត្ថកិច្ចប៉ុស្តិ៍នគរបាលឃុំពពេលឱ្យចាត់ការតាមនីតិវិធី។ ក្នុងរឿងនេះខ្លួនទាមទារសំណង និងជំងឺចិត្តចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល និង សុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការសួរដេញដោលនៅក្នុងអង្គសវនាការ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយបំភ្លឺរបស់សាក្សី ក៏ដូចជាពិនិត្យឯកសារផ្សេងៗដែលមានក្នុងសំណុំរឿងខាងលើនេះឃើញថា: កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ស្ថិតនៅចំណុចភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានអំពើលួចម៉ូតូមួយគ្រឿងម៉ាកស៊ូម៉ីអ៊ីចដែលបានកើតឡើងពិតប្រាកដមែន។ ត្បិតតែនៅពេលនេះជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានឆ្លើយបដិសេធប្រាកដមែន ក៏ប៉ុន្តែបើផ្អែកទៅលើឯកសារផ្សេងៗដែលមាននៅក្នុងសំណុំរឿង ឃើញថាជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ដោយផ្អែកទៅតាមចម្លើយរបស់ឈ្មោះ [redacted] **ស៊ីដេត** ដែលបានឆ្លើយបញ្ជាក់យ៉ាងច្បាស់ទៅលើឈ្មោះ [redacted] **សំអឿន** ។ ដូច្នេះចម្លើយដោះសាររបស់ជនជាប់ចោទនៅពេលនេះគឺគ្រាន់តែជាចម្លើយដោះសារមួយយកតែការរួចផុតពីបទចោទតែប៉ុណ្ណោះ។ ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទលើជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ ពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌទុកដដែល និងសូមសុំដល់តុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទនេះតាមកំណត់ច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានធ្វើសេចក្តីសន្និដ្ឋានការពារដល់កូនក្តីខ្លួនថា: កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ស្ថិតនៅចំណុចភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានអំពើលួចម៉ូតូបានកើតឡើងដែលជនជាប់ចោទឈ្មោះ [redacted] **ស៊ីដេត** បានប្រព្រឹត្តពិតមែន ប៉ុន្តែបើមើលទៅលើភាពពិតជាក់ស្តែងឈ្មោះ [redacted] **ស៊ីដេត** គាត់បានឆ្លើយសារភាពថា: គាត់បានលួចម៉ូតូនោះរួចហើយយកទៅលក់នៅខាងជើងផ្សារសំរោងយ៉ោងដែលមានចម្ងាយ ៥គីឡូ ហើយបើតាមការវាស់ជាក់ស្តែងពីចំណុចផ្សារសំរោងយ៉ោងទៅដល់ភូមិហុនមានជិតផ្ទះកូនក្តីរបស់ខ្ញុំឈ្មោះ [redacted] **សំអឿន** នេះ គឺមានចម្ងាយ ៧គីឡូម៉ែត្រឯណោះ មិនតែប៉ុណ្ណោះកន្លែងដែលទទួលទិញអេតចាយចាប់តាំងពីផ្សារសំរោងយ៉ោងមកដល់ផ្ទះរបស់កូនក្តីខ្ញុំ គឺមានកន្លែងលក់អេតចាយចំនួន ០៥កន្លែងឯណោះ។ អញ្ចឹងដូច្នេះចំពោះម៉ូតូដែលឈ្មោះ [redacted] **ស៊ីដេត** បានលួចយកមកលក់នោះ គឺមិនដឹងថាគាត់បានយកទៅលក់នៅកន្លែងណាឱ្យប្រាកដនោះទេ។ ម្យ៉ាងវិញទៀតចំពោះចម្លើយរបស់ឈ្មោះ [redacted] **ស៊ីដេត** ដែលបានឆ្លើយនៅដំណាក់កាលអយ្យការកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ក៏ឈ្មោះ [redacted] ស៊ីដេត បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថាគាត់បានយកម៉ូតូនោះទៅលក់នៅខាងជើងផ្សារសំរោងយ៉ោងមែន ប៉ុន្តែឈ្មោះ [redacted] **ស៊ីដេត** មិនបានស្គាល់ឈ្មោះអ្នកដែលទិញអេតចាយនោះទេ ទើបតែនៅពេលដែលមានចម្លើយនៅពេលដែលជំនុំជម្រះមានឈ្មោះកូនក្តីរបស់ខ្ញុំបាទ។ ជាក់ស្តែងនៅនីតិវិធីស៊ើបសួរ និងនៅក្នុងដីកាដំណោះស្រាយក៏បានលើកលែងលើអញ្ញាតជនដែលពាក់ព័ន្ធនឹងអំពើទទួលផលចោរកម្មនេះផងដែរ ដោយមិនបានពាក់ព័ន្ធនឹងកូនក្តីរបស់ខ្ញុំនោះទេ។ ម្យ៉ាងវិញទៀត



Scanned with CamScanner

ចម្លើយរបស់កូនក្តីខ្ញុំបាទបានឆ្លើយបំភ្លឺចមកហើយដែរក្នុងនាមជាសាក្សីបានបញ្ជាក់ថាគាត់មិនបានទិញម៉ូតូពីឈ្មោះ [redacted] **ស៊ីដេត** នោះទេ។ ដូច្នេះសាច់រឿងនេះ គឺគ្រាន់តែជាការឆ្លើយតែភាគីម្ខាងរបស់ជនជាប់ចោទឈ្មោះ [redacted] **ស៊ីដេត** ជាងនោះទៀតសោតជនជាប់ចោទឈ្មោះ [redacted] **ស៊ីដេត** តុលាការក៏បានចេញដីកាកោះហៅឱ្យមកចូលសវនាការដើម្បីតទល់ជាមួយនឹងកូនក្តីខ្ញុំបាទដែរ ក៏ប៉ុន្តែមិនឃើញមានវត្តមានរបស់គេនៅក្នុងពេលសវនាការនេះនោះទេ។ ដូច្នេះបើយោងទៅតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វាក្យខណ្ឌទី២ ចែងថា "តុលាការថ្លឹងថ្លែងដោយឥស្សរៈចិត្តអំពីតម្លៃភស្តុតាងដែលបានដាក់ជូនមកតុលាការពិនិត្យដោយផ្អែកលើជំនឿដោយភាពស្មោះត្រង់" ដោយយោងតាមមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌទី១ បានចែងថា "វិមតិសង្ស័យត្រូវតែបានជាផលប្រយោជន៍ទៅលើជនជាប់ចោទជានិច្ច"។ ដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអឿន** សូមស្នើសុំដល់តុលាការមេត្តាលើកលែងបទចោទប្រកាន់មកលើកូនក្តីខ្ញុំបាទពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-សំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ថាៈ ខ្ញុំសូមស្នើសុំដល់តុលាការមេត្តាកុំចោទប្រកាន់មកលើរូបខ្ញុំបាទអី ព្រោះនៅថ្ងៃដែលមានរឿងហេតុកើតឡើងនោះ គឺខ្ញុំបាទពិតជាពុំបានទទួលទិញម៉ូតូពីឈ្មោះ [redacted] **ស៊ីដេត** នោះទេ។

**-ក្រោយពីបាន** ស្តាប់ចម្លើយរបស់ជនជាប់ចោទ។

**-ក្រោយពីបាន** ស្តាប់ចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **រិទ្ធិ**។

**-ក្រោយពីបាន** ស្តាប់អំណានចម្លើយរបស់ឈ្មោះ [redacted] **ស៊ីដេត**។

**-ក្រោយពីបាន** ស្តាប់អំណានចម្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**-ក្រោយពីបាន** ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង ។

**-ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

**-ក្រោយពីបាន** ស្តាប់សេចក្តីសន្និដ្ឋានសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

**-ក្រោយពីបាន** ស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ ។

**-ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តាមសេចក្តីចម្លងបណ្តឹងទាស់លេខៈ ២៥/២០២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** បានប្តឹងចូលមកសាលាដំបូងខេត្តតាកែវ គឺស្ថិតនៅក្នុងអំឡុងពេលដែលច្បាប់បានទុកសិទ្ធិឱ្យពិរុទ្ធជនប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះនាំឱ្យតុលាការអាចលើកយកសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦២៣ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ មកជំនុំជម្រះសារឡើងវិញបាន។

២-តាមសាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ពិរុទ្ធជនមានសិទ្ធិប្តឹងទាស់លើសាលក្រមដែលតុលាការបានសម្រេចសេចក្តីកំបាំងមុខរបស់ខ្លួនតាមបញ្ញត្តិមាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយចំពោះជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ



Scanned with CamScanner

(កើតឆ្នាំ១៩៧៤) បានប្តឹងទាស់លើសាលក្រមខាងលើនេះដោយបានប្តឹងទាស់ត្រង់សេចក្តីសម្រេចទាំង មូលនៃសាលក្រម។ ហេតុនេះគប្បីតុលាការអាចលើកយកសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦២៣ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ ទទួលយកបណ្តឹងទាស់នេះ និងសម្រេចលើអង្គសេចក្តីជាថ្មីម្តងទៀតបានតាមបញ្ញត្តិមាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-តាមចម្លើយរបស់ឈ្មោះ [redacted] **ស៊ីដេត** ចម្លើយបំភ្លឺរបស់សាក្សី និងអំណានចម្លើយបំភ្លឺរបស់ដើមបណ្តឹង ព្រមទាំងពិនិត្យលើឯកសារនានាដែលមានក្នុងសំណុំរឿង បញ្ជាក់ឱ្យឃើញថាៈ កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ស្ថិតនៅចំណុចភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានឈ្មោះ [redacted] **ស៊ីដេត** បានធ្វើសកម្មភាពលួចម៉ូតូមួយគ្រឿងម៉ាកស៊ូម៉ូអ៊ិចពណ៌បៃតងពាក់ស្លាកលេខ៖ 10-0480 លេខតួ៖ 5117526 និងលេខម៉ាស៊ីន៖ 0117526 ដែលជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] **ឌីណា**។ ក្រោយពេលធ្វើសកម្មភាពលួចរួចហើយនោះឈ្មោះ [redacted] **ស៊ីដេត** ក៏បានយកម៉ូតូនោះទៅលក់ឱ្យឈ្មោះ [redacted] **សំអឿន** ដែលជាអ្នកទិញអេតចាយ ស្ថិតនៅចំណុចខាងជើងផ្សារសំរោងយ៉ាង បានប្រាក់ចំនួន ១០០.០០០ (ដប់ម៉ឺន) រៀលប្រាកដមែន។

៤-តាមចម្លើយបដិសេធរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ដែលបានឆ្លើយថាៈ ចំពោះរឿងហេតុដែលបានចោទប្រកាន់នេះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយខ្លួនមិនបានទិញម៉ូតូពីឈ្មោះ [redacted] **ស៊ីដេត** នោះទេ ដែលចម្លើយនេះ គឺគ្រាន់តែជាការឆ្លើយដោះសារដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវនូវអំពើដែលខ្លួនដែលបានប្រព្រឹត្តតែប៉ុណ្ណោះ។ ផ្ទុយទៅវិញផ្អែកតាមចម្លើយរបស់ឈ្មោះ [redacted] **ស៊ីដេត** ក៏ដូចជារបាយការណ៍ និងឯកសារនានាដែលមានក្នុងសំណុំរឿងខាងលើនេះ បញ្ជាក់ឱ្យឃើញថាៈ នៅថ្ងៃកើតហេតុក្រោយពេលដែលមានអំពើលួចម៉ូតូមួយគ្រឿងម៉ាកស៊ូម៉ូអ៊ិចពណ៌បៃតង ពាក់ស្លាកលេខ៖10-0480 លេខតួៈ 5117526 និងលេខម៉ាស៊ីនៈ 0117526 ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) រៀល បានកើតឡើងនៅចំណុចភូមិត្រពាំងកក់ ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ដែលប្រព្រឹត្តដោយឈ្មោះ [redacted] **ស៊ីដេត** ហើយនោះ គឺជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពិតជាបានទិញម៉ូតូនេះពីឈ្មោះ [redacted] **ស៊ីដេត** ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) រៀលប្រាកដមែន។

៥-យល់ឃើញថាៈ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ដែលបានទទួលទិញម៉ូតូមួយគ្រឿងម៉ាកស៊ូម៉ូអ៊ិចពណ៌បៃតង ពាក់ស្លាកលេខ៖ 10-0480 លេខតួៈ 5117526 និងលេខម៉ាស៊ីនៈ 0117526 ពីឈ្មោះ [redacted] **ស៊ីដេត** ក្នុងតម្លៃ ១០០.០០០ (ដប់ម៉ឺន) រៀល ដែលឈ្មោះ [redacted] **ស៊ីដេត** បានធ្វើសកម្មភាពលួចពីម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] **ឌីណា** ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិស្របច្បាប់របស់អ្នកដទៃទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៦-យល់ឃើញថាៈ ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤) គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសព្រហ្មទណ្ឌដែល កើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៧-យល់ឃើញថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤) ពីបទៈ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពី

Scanned with CamScanner

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៨-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយស្នើសុំដល់តុលាការសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សំអឿន** តាមច្បាប់ពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថាៈ ការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ ហេតុនេះគប្បីតុលាការសម្រេចតាមការប្តឹងសុំនេះ។

៩-តាមសេចក្តីសន្និដ្ឋានសុំរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ដោយសុំដល់តុលាការសម្រេចលើកលែងបទចោទប្រកាន់មកលើកូនក្តីខ្លួនឈ្មោះ [redacted] **សំអឿណ** ពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។ តុលាការយល់ឃើញថាៈ ការស្នើសុំនេះពុំមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់នោះទេ ហេតុនេះគប្បីតុលាការពុំទទួលយកមកពិចារណាឡើយ។

១០-យល់ឃើញថាៈ ការប្តឹងទាស់របស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ទៅនឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ដែលតុលាការបានសម្រេចដោយកំបាំងមុខជនជាប់ចោទខាងលើនេះ គឺមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ ហេតុគប្បីតុលាការពិចារណាចំពោះការផ្តន្ទាទោសលើជនជាប់ចោទខាងលើនេះឡើងវិញ។

១១-យល់ឃើញថាៈ ថ្វីត្បិតតែនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ពុំបានសារភាពទទួលស្គាល់នូវកំហុសរបស់ខ្លួនក៏ដោយ ក៏ប៉ុន្តែឃើញថាអំពើដែលបានកើតឡើងនេះក៏ពុំបានបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរនោះទេ និងនាពេលសវនាការជនជាប់ចោទរូបនេះក៏មានអាកប្បកិរិយាល្អ មួយវិញទៀតឃើញថាចំពោះបទល្មើសខាងលើនេះក៏ជាបទមជ្ឈិមផងដែរ។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទរូបនេះកំណត់ចំនួន **២ (ពីរ) ឆ្នាំ** និងសម្រេចឱ្យជនជាប់ចោទរូបនេះអនុវត្តទោសនៅក្នុងពន្ធនាគារកំណត់ត្រឹមចំនួន **០១ (មួយ) ខែ និង ១៩ (ដប់ប្រាំបួន) ថ្ងៃ** ហើយទោសដែលនៅសេសសល់ឱ្យអនុវត្តការព្យួរទោសធម្មតាតាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៧ កថាខណ្ឌទី១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

១២-យល់ឃើញថាៈ តាមសាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ដែលបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ដាក់ពន្ធនាគារកំណត់ចំនួន **០៣ (បី) ឆ្នាំ** ពីបទៈ **ទទួលផលចោរកម្ម** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។ ក៏ប៉ុន្តែក្រោយពេលតុលាការទទួលសេចក្តីចម្លងបណ្តឹងទាស់លេខៈ ២៥/២០២៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ជនជាប់ចោទឈ្មោះ [redacted] **សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤) នៅក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើនេះមកបើកសវនាការដេញដោលម្តងទៀតរួចហើយៗជននេះត្រូវបានតុលាការកែប្រែ និងសម្រេចសេចក្តីសារជាថ្មីតាមអំណាចសាលក្រមព្រហ្មទណ្ឌខាងលើនេះ។ ហេតុដូច្នេះគប្បីតុលាការសម្រេចសេចក្តីតម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការដដែល លើកលែងតែចំណុចទី១ (១.២) និងចំណុចទី៣ ត្រូវលើកយកមកសម្រេចសារជាថ្មី។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៤៧ (ឆ) ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការដដែល លើកលែងតែចំណុច**ទី១ (១.២) និងទី៣** ត្រូវយកមកសម្រេចសារជាថ្មី។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ **[redacted] សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤) ដាក់ពន្ធនាគារកំណត់ចំនួន **០២ (ពីរ) ឆ្នាំ** តែទោសនេះត្រូវអនុវត្តទោសក្នុងពន្ធនាគារត្រឹមចំនួន **០១ (មួយ) ខែ និង ១៩ (ដប់ប្រាំបួន) ថ្ងៃ** ទោសដែលនៅសល់ត្រូវអនុវត្តការព្យួរទោសធម្មតា ពីបទៈ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចភូមិហនុមាន ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៣-បញ្ឈប់អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនពិរុទ្ធជនលេខៈ ១០៨/ត្រ.ព ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមជំនុំជម្រះ លើជនជាប់ចោទឈ្មោះ **[redacted]សំអឿន** ភេទប្រុស អាយុ៥១ឆ្នាំ (កើតឆ្នាំ១៩៧៤)។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ **[redacted]សំអឿន**។

-ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)

ថ្ងៃចន្ទ ១៣រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

តាកែវ,ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

តាកែវ,ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner